# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 890

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : គម្រោងគ្រប់គ្រងនិងអភិរក្សដីសើមអាងទន្លេមេគង្គក្រោម

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/19

កាលបរិច្ឆេទបញ្ចប់គម្រោង 30/12/22

៣. ចំណាយគម្រោងសរុប $4,862,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងបរិស្ថាន

RESPONSIBLE UNIT Department of Freshwater Wetlands Conservation in General Directorate of Administration for Nature Conservation and Protection

អង្គភាពទទួលខុសត្រូវ នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទានៈ បញ្ចូលគ្នារវាងថវិការ និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៣- ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងមានសារៈសំខាន់ណាស់ ក្នុងការរួមចំណែកដើម្បីសម្រេចឱ្យបាននូវយុទ្ធសាស្រ្តចតុកោណ ដែលជួយថែរក្សា ធនធានធម្មជាតិក្នុងតំបន់ដីសើមនៅអាងទន្លេមេគង្គភាគខាងក្រោម ជាពិសេសតំបន់រ៉ាមសារព្រែកទាល់ រួមទាំង ការបង្កើនជីវភាពរស់នៅរបស់សហគមន៍តំបន់ការពារធម្មជាតិ តាមរយៈការផ្តល់សេវាផ្សេងៗ អភិវឌ្ឍន៍អេកូទេសចរណ៍ និងការអភិរក្សជីវៈចម្រុះជាដើម។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

សៀមរាប, បាត់ដំបង,

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

គោលបំណងសំខាន់ៗរបស់គម្រោងគ្រប់គ្រង និងអភិរក្សតំបន់ដីសើមអាងទន្លេមេគង្គក្រោម គឺ៖
- រួមចំណែកក្នុងការស្តារឡើងវិញ ការអភិរក្ស និងការគ្រប់គ្រងសេវាកម្មប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើម ដើម្បីបង្កើន នូវជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន នៅក្នុងតំបន់ដីសើម ដែលត្រូវបានជ្រើសរើសទីតាំង
- រួមចំណែកដល់ការពង្រឹងចំណេះដឹងមូលដ្ឋានសម្រាប់តំបន់ដីសើមថ្នាក់តំបន់ និងការចែករំលែកព័ត៌មានផ្សេងៗ។

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

គម្រោងចែកចេញជា ៣សមាសភាគផ្សេងៗគ្នា ៖ សមាសភាគទី១ ថ្នាក់តំបន់ (ត្រូវបានអនុវត្តដោយគណៈកម្មការទន្លេមេគង្គMRC-S) សមាសភាគទី២ ថ្នាក់ជាតិ (ត្រូវបានអនុវត្តដោយប្រទេសឡាវ និងព្រះរាជាណាចក្រកម្ពុជា)។ ដោយឡែកប្រទេសកម្ពុជា អនុវត្តនៅតំបន់រ៉ាមសារស្ទឹងត្រែង និងតំបន់រ៉ាមសារ ព្រែកទាល់ ដែលគម្រោងស្ថិតនៅក្រោមការអនុវត្តរបស់សមាសភាគកម្ពុជា ខាងក្រោមនេះ ជាចង្កោមសកម្មភាពនិមួយៗ បានមកពីវិភាគទានហិរញ្ញវត្ថុ រួមមាន៖

លទ្ធផលទី១៖ ការអភិវឌ្ឍន៍ផែនការគ្រប់គ្រងពីថ្នាក់ក្រោម ដោយមានការសម្របសម្រួល និងអនុម័តដោយក្រុមការងារ និងថ្នាក់ឃុំ សកម្មភាពចម្បងៗ មាន៖

- អភិវឌ្ឍ និងអនុម័តគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងតំបន់ដីសើម
- បញ្ចូលផែនការសកម្មភាព ៥ឆ្នាំ សម្រាប់ការការពារតំបន់ដីសើម ការអភិរក្ស និងការប្រើប្រាស់ប្រកបដោយនិរន្តភាពនៅតំបន់សហគមន៍
- អភិវឌ្ឍកញ្ចប់សកម្មភាពដដែល ដើម្បីបង្កើនការគ្រប់គ្រងតំបន់ដីសើមឱ្យកាន់តែប្រសើរ

លទ្ធផលទី២៖ បង្កើនការគ្រប់គ្រងតំបន់ដីសើម តាមរយៈកិច្ចសហប្រតិបត្តិការណ៍ សកម្មភាពចម្បងៗ រួមមាន៖

- ការអនុវត្តលើផែនការគ្រប់គ្រងតំបន់ដីសើម(អាជ្ញាធរមូលដ្ឋាន សហគមន៍ និងភ្នាក់ងារទទួលខុសត្រូវ)
- ការកំណត់ព្រំប្រទល់ទីតាំង
- ការកំណត់តំបន់គ្រប់គ្រងឱ្យបានច្បាស់លាស់
- ការបង្កើននូវហេដ្ឋារចនាសម្ព័ន្ធតំបន់ការពារ
- ការចូលរួមពីសហគមន៍ក្នុងការឃោមល្បាតឱ្យបានតឹងរឹង
- ការគាំទ្រ និងការបង្កើតសហគមន៍ជលផលថ្មី (CFi) និងតំបន់ការពារសហគមន៍
- គាំទ្រដល់សហគមន៍ដែលពឹងផ្អែកលើការចិញ្ចឹមជីវិតនៅតំបន់ដីសើម (ឧ. ការបង្កើនផលិតផលត្រីព្រៃឈើ និងកសិកម្ម)
- ការបង្កើននូវហេដ្ឋារចនាសម្ព័ន្ធសង្គម
- ជួយសហគមន៍ក្នុងការបង្កើតផែនការថវិកាសម្រាប់ទាញយកផលប្រយោជន៍ពីអេកូទេសចរណ៍
- សាងសង់មជ្ឈមណ្ឌលសម្រាប់អ្នកទស្សនា
- ការស្តារឡើងវិញប្រភេទរុក្ខជាតិតូចៗ និងព្រៃឈើ
- កាត់បន្ថយចម្រោះតាមបឹង និងទន្លេ

លទ្ធផលទី៣៖ សមត្ថភាពក្នុងការគ្រប់គ្រងតំបន់ដីសើមប្រកបដោយនិរន្តរភាព និងការពង្រឹងក្រុមការងារទទួលខុសត្រូវ សហគមន៍ និងអ្នកជាប់ពាក់ព័ន្ធផ្សេងៗ ស្របតាមយន្តការតំបន់រ៉ាមសារ សកម្មភាពចម្បងៗ រួមមាន៖

- ពង្រឹងសមត្ថភាពសមាជិកគណៈកម្មការរ៉ាមសារ សហគមន៍ និងបុគ្គលិករដ្ឋាភិបាលដែលទទួលបន្ទុក
- ជួយដល់គណៈកម្មការរ៉ាមសារក្នុងការត្រួតពិនិត្យលើការគ្រប់គ្រងតំបន់
- បង្កើនការអប់រំតាមសាលានៅតំបន់រ៉ាមសារ អំពី តម្លៃ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី
- ការបង្កើត និងអនុវត្តប្រព័ន្ធត្រួតពិនិត្យ
- គាំទ្រដល់ការគ្រប់គ្រងតំបន់ដីសើម ចំពោះការសម្រេចចិត្តលើគម្រោងដីសើម និងការប្រមូលទិន្នន័យនៅទីវាល ដើម្បីផ្តល់ទិន្នន័យឱ្យគណៈកម្មាការទន្លេមេគង្គ
- ផ្តល់ការបណ្តុះបណ្តាល និងគាំទ្រការអនុវត្តលើការគ្រប់គ្រងតំបន់រ៉ាមសារដែលទទួលបានជោគជ័យ ទៅតំបន់ផ្សេងទៀត

លទ្ធផលទី៤៖ ការធានាហិរញ្ញប្បទានប្រកបដោយនិរន្តភាពក្នុងការការពារជីវចម្រុះ និងធនធានដីសើម សកម្មភាពចម្បងៗ រួមមាន៖

- ជួយក្រសួងបរិស្ថានក្នុងការបញ្ចប់ និងអនុវត្តផែនការអេកូទេសចរណ៍នៅតំបន់ស្នូលព្រែកទាល់
- អភិវឌ្ឍ និងចងក្រងបទដ្ឋានគតិយុត្ត ដើម្បីធានាផលចំណូលក្នុងមូលដ្ឋាន នៅតំបន់រ៉ាមសារ
- ការប្រមូលផលចំណូលផ្សេងៗ
- ការផ្លាស់ប្តូរគម្រោងមូលនិធិ នៃការគ្រប់គ្រងតំបន់ការពារ តាមរយៈផលចំណូលពីមូលដ្ឋាន។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

គម្រោងនេះ បានចូលរួមចំណែកយ៉ាងមានប្រសិទ្ធភាពដល់គណៈកម្មការទន្លេមេគង្គ និងជួយទ្រទ្រង់សមត្ថភាពដល់ប្រទេសដែលជាសមាជិកក្នុងការគ្រប់គ្រងបញ្ហាក្នុងអាងទន្លេ ជាពិសេសចាប់ផ្ដើមពីការអភិវឌ្ឍន៍វារី អគ្គិសនី និងបម្រែបម្រួលអាកាសធាតុ (កម្រិតប៉ះពាល់)។ មានការទទួលខុសត្រូវជាន់គ្នាលើការគ្រប់គ្រងតំបន់ ដីសើម ដូចនេះនៅពេលមានកំណែទម្រង់ផ្លូវច្បាប់ម្ដងៗ គឺធ្វើការបែងចែកគ្នាតាមគោលនយោបាយ និងច្បាប់ផ្សេងៗ ចំពោះការអភិវឌ្ឍន៍ការគ្រប់គ្រងតំបន់ដីសើមឱ្យមានប្រសិទ្ធភាពកាន់តែប្រសើរ ដែលអាចអនុវត្ត និងផ្សព្វផ្សាយបន្តពីថ្នាក់តំបន់ ក៏អាចជួយការអភិរក្សតំបន់ដីសើមក្នុងថ្នាក់ជាតិ ដែលនាំប្រយោជន៍ទៅថ្នាក់តំបន់ និងពិភពលោកផងដែរ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អាជ្ញធរជាតិ និងថ្នាក់ក្រោមជាតិនឹងទទួលបានផលប្រយោជន៍ពីការអនុវត្តគម្រោងតាមរយៈការពង្រឹងនិងការកសាងសមត្ថភាពលើការគ្រប់គ្រងអាងទន្លេមេគង្គខាងក្រោម ជាពិសេសតំបន់រ៉ាមសារព្រែកទាល់ នៅខេត្តបាត់ដំបង។ នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាបនៃក្រសួងបរិស្ថាន នាយកដ្ឋានអភិរក្សជលផលនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ គណៈកម្មការជាតិទន្លេមេគង្គកម្ពុជា ជាអាជ្ញធរថ្នាក់ជាតិ និងអាជ្ញធរថ្នាក់ក្រោមជាតិរួមមាន អាជ្ញធរថ្នាក់ខេត្ត មន្ទីររដ្ឋបាលជលផលបរិស្ថានខេត្តបាត់ដំបង។

គម្រោងនេះ សំខាន់ផ្ដោតលើការពង្រឹងសមត្ថភាពសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងដីសើមឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ នៅតំបន់រ៉ាមសារព្រែកទាល់មានភូមិចំនួន ០៥ មានព្រំប្រទល់នៅជិតតំបន់ស្នូលព្រែកទាល់(តំបន់រ៉ាមសារ) នៅក្នុងភូមិសាស្ត្រតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប តំបន់ជុំវិញឋបនីយជីវមណ្ឌលបឹងទន្លេសាប។ ភូមិទាំងនេះ ស្ថិតនៅតំបន់វាលទំនាបបឹងទន្លេសាបមានប្រជាជនជាង ១០០០០នាក់ រស់នៅក្នុងសហគមន៍ និងភាគច្រើនរស់នៅភូមិអណ្តែតទឹកជាជនជាតិវៀតណាម។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | ត្រូវបានបញ្ចប់ |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនេះ នឹងធ្វើការផ្លាស់ប្តូរផ្នត់គំនិតរបស់អាជ្ញធរមូលដ្ឋាន តាមរយៈការបង្កើនចំណេះដឹងផ្នែកបរិស្ថាន និងការបង្កើតឱកាសការងារផ្សេងៗទៀត។ តំបន់ការពារសហគមន៍ បានធ្វើការផ្លាស់ប្តូរពីសហគមន៍ជលផល ដែលជាកម្មសិទ្ធផ្ទាល់ទៅជាតំបន់ដីសើម លើសពីនេះទៀតប្រព័ន្ធអេកូទេសចរណ៍ និងសេវាកម្មគាំទ្រផ្សេងៗ ក៏បានផ្លាស់ប្តូរនូវកម្រិតជីវភាពរបស់សហគមន៍មូលដ្ឋានឱ្យកាន់តែប្រសើរបានមួយកម្រិតទៀតផង។

ប្រភេទព្រៃលិច និងសត្វព្រៃ ការគ្រប់គ្រងគុណភាពទឹក និងសំណល់ និងប្រសិទ្ធភាពក្នុងការការពារផ្នែកបរិស្ថាន និងជីវចម្រុះនឹងនៅតែបន្តធ្វើការត្រួតពិនិត្យនៅក្នុងតំបន់រ៉ាមសារ។ បន្ថែមពីនេះទៀត ការអភិរក្សប្រភេទសត្វស្លាបទឹក និងសត្វស្លាបទេសន្តរប្រទេសប្រកបដោយនិរន្តភាព នៅពេលមានការពង្រឹងការយាមល្បាតរបស់ឧទ្យានុរក្ស ការមើលបន្ទាយពងកូនសត្វស្លាប និងកម្មវិធីស្តារជម្រកសត្វស្លាប ក៏ត្រូវបានអនុវត្តផងដែរ។

១៩. ការប្រែប្រួល អាកាសធាតុ

| | |
|---|---|
| ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? | មាន |
| ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស | ការបន្សាំ |

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
| --- | --- | --- |
| ១៩. ជីវៈចម្រុះ និងការអភិរក្ស<br>២០. ការកាត់បន្ថយ ហានិភ័យ និងគ្រោះមហន្តរាយ | 80 | **ទាក់ទងខ្លាំង** |

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការបង្ការ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

ក្នុងនោះទាំងបុរស និងស្ត្រីបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោង និងអនុវត្តលើសកម្មភាពចម្បងៗផងដែរ ផ្តោតលើការចិញ្ចឹមជីវិត ការទទួលផលពីអេកូទេសចរណ៍ និងការអភិរក្សជាដើម។ ទោះជាយ៉ាងណាក៏ដោយ ភាគច្រើនជាស្ត្រីប្រកបរបរចិញ្ចឹមជីវិតតិចតួចដែលនៅជិតៗផ្ទះឡើយ ចំណែកបុរសវិញ ធ្វើការងារជាទីប្រឹក្សា ដើម្បីជានាឱ្យអាជីវកម្មប្រកបដោយនិរន្តរភាព។ ជារួមទាំងបុរស និងស្ត្រីមានសិទ្ធស្មើគ្នាក្នុងការចូលរួមក្នុងការអភិវឌ្ឍន៍ផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការគ្រប់គ្រងគម្រោង តាមរយៈការបង្កើនការយល់ដឹង និងការពិគ្រោះយោបល់ លើការប្រជុំ និងសិក្ខាសាលានានា។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិមានសមត្ថភាពគ្រប់ គ្រាន់សម្រាប់អនុវត្តគម្រោងក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ និងទីប្រឹក្សា អន្តរជាតិ GITEC។

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

កិច្ចព្រមព្រៀងហិរញ្ញប្បទាន និងកិច្ចព្រមព្រៀងដាច់ដោយឡែករវាងព្រះរាជាណាចក្រកម្ពុជា និងធនាគារអភិវឌ្ឍន៍KfW ត្រូវបានចុះហត្ថលេខានៅខែមេសា ឆ្នាំ២០១៧ ទីប្រឹក្សាអន្តរជាតិGITEC ក៏ត្រូវបានចុះកុងត្រាសម្រាប់ការផ្តល់សេវាកម្មផ្សេងៗ ដែលត្រូវធ្វើការនៅនាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប នៃក្រសួងបរិស្ថាន។

អង្គភាពគ្រប់គ្រងគម្រោងថ្នាក់ជាតិ និងការិយាល័យអនុវត្តគម្រោងថ្នាក់ខេត្ត សម្រាប់តំបន់រ៉ាមសារព្រែក ទាល់ ត្រូវបានអនុម័តកាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៧ ដោយការសម្រេចរបស់ ក្រសួងបរិស្ថានមានបុគ្គលិក ២៦នាក់រួមមាន ឧទ្យានុរក្ស មន្រ្តីបច្ចេកទេសថ្នាក់ខេត្ត។ បុគ្គលិកដែលត្រូវអនុវត្តគម្រោងបានចាត់បញ្ជូនដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់និងនេសាទ គណៈកម្មាការជាតិទន្លេមេគង្គកម្ពុជា និងក្រសួងបរិស្ថាន ជាពិសេសមន្ទីរបរិស្ថាន ជលផលខេត្ត។

គណៈកម្មាការអចិន្ត្រៃយ៍របស់គម្រោង បានបង្កើតឡើងនៅខែវិច្ឆិកា ឆ្នាំ២០១៧ ដែលមានសមាជិកចំនួន១១នាក់ បានចាត់តាំងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន និងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងទេសចរណ៍ គណៈកម្មាការជាតិទន្លេមេគង្គកម្ពុជា និងអភិបាលរងខេត្តបាត់ដំបង។

កាលពីថ្ងៃទី១៨-២៦ ខែវិច្ឆិកា ឆ្នាំ២០១៧ អ្នកគ្រប់គ្រងគម្រោង KfW ទីប្រឹក្សាអន្តរជាតិ បានធ្វើបច្ចុប្បន្នអំពីស្ថានភាពទូទៅនៅតំបន់រ៉ាមសារស្ទឹងត្រែង និងអង្គការក្រៅរដ្ឋាភិបាលក៏បានផ្តល់នូវជំនួយទាំងបច្ចេកទេស និងជំនាញផងដែរ។

នៅចុងខែធ្នូ ឆ្នាំ២០១៧ ក្រុមការងារអនុវត្តគម្រោងថ្នាក់ជាតិបានដាក់លិខិតផ្លូវការចំនួន០២ ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទី១ ការស្នើសុំមន្រ្តីចំនួន០៣នាក់ សម្រាប់គ្រប់គ្រងគម្រោង និងការទូទាត់ចំណាយផ្សេងៗ ទី២ ស្នើសុំបើកគណនេយ្យចំនួន ០២ នៅធនាគារអេស៊ីលីដា និង ធនាគារជាតិកម្ពុជា។

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ក្រុមការងារបានបញ្ចប់ផែនការការងារ និងថវិកា ហើយបានដាក់ទៅKfW សម្រាប់ពិនិត្យឡើងវិញ និងផ្តល់ជាយោបល់ផ្សេងៗ។ ក្រុមការងារក៏បានរៀបចំផែនការការងារនិងថវិកា ឆ្នាំ២០១៨ សម្រាប់ប្រាក់បៀវត្សរ៍មន្រ្តីផងដែរ។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

សក្តានុពលរបស់ដៃគូអភិវឌ្ឍក្នុងការអនុវត្តគម្រោង គឺការផ្តល់សេវាផ្សេងៗ ការពិគ្រោះយោបល់ និងការគ្រប់គ្រងហិរញ្ញប្បទាន។ គិតតាមអត្រា របស់ធនាគារអេស៊ីលីដាប្តូរប្រាក់ នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ (១យូរ៉ូ ស្មើនឹង១.១០៥០ដុល្លាអាមេរិក)។ ផែនការថវិកាបានកែសម្រួលនៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២០ ហើយកំពុងរង់ចាំអនុម័តដោយម្ចាស់ជំនួយ។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 131.5 | 0.0 | 139.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 66.6 | 0.0 | 66.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារ:និងរដ្ឋបាល | 17.5 | 0.0 | 17.5 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 47.4 | 0.0 | 55.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 892.5 | 0.0 | 501.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 221.4 | 0.0 | 50.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារ: | 24.5 | 0.0 | 4.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 57.5 | 0.0 | 28.7 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 589.1 | 0.0 | 417.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 1,024.0 | 0.0 | 640.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ថវិកាជាតិ | 148.8 | 0.0 | 97.1 | 0.0 | 0.0 | 0.0 | 0.0 | |
| សាច់ប្រាក់សុទ្ធ | 148.8 | 0.0 | 97.1 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 875.2 | 0.0 | 543.1 | 0.0 | 0.0 | 0.0 | 0.0 | |
| Kreditanstalt fuer Wiederaufbau | 875.2 | 0.0 | 543.1 | 0.0 | 0.0 | 0.0 | 0.0 | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 1,024.0 | 0.0 | 640.2 | 0.0 | 0.0 | 0.0 | 0.0 | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: